តម្លាភាពកម្ពុជា
TRANSPARENCY INTERNATIONAL
Cambodia

# សេចក្តីប្រកាសព័ត៌មាន

## នៅថ្ងៃអបអរទិវាជាតិ និងអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ
## អង្គការតម្លាភាពកម្ពុជាសូមអំពាវនាវឱ្យប្រជាពលរដ្ឋកម្ពុជាចូលរួមប្រឆាំង
## អំពើពុករលួយដើម្បីការអភិវឌ្ឍនិរន្តរភាព

**រាជធានីភ្នំពេញថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៥** – ឆ្លៀតក្នុងឱកាសអបអរទិវាជាតិ និងអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយ អង្គការតម្លាភាពកម្ពុជាសូមលើកទឹកចិត្តឱ្យប្រជាជនកម្ពុជាទាំងអស់ចូលរួមប្រឆាំងអំពើពុករលួយ ដើម្បីធានាថាមនុស្សគ្រប់រូបនឹងទទួលបាននូវផលប្រយោជន៍ពីការអភិវឌ្ឍដែលមាននិរន្តរភាព ។

អំពើពុករលួយដែលត្រូវបានឱ្យនិយមន័យថាជាការរំលោភអំណាចដែលទទួលបានពីប្រជាពលរដ្ឋដើម្បីទទួលបានប្រយោជន៍ឯកជន គឺជាមូលហេតុបង្កឱ្យបញ្ហាភាពក្រីក្រ និងវិសមភាពកាន់តែធ្លាក់ដុនដាប់ដោយសារអំពើពុករលួយរារាំងដំណើរការ និងរចនាសម្ព័ន្ធដែលទ្រទ្រង់ដល់ការអភិវឌ្ឍ ។ អំពើពុករលួយក៏ធ្វើឱ្យវិធាននៃច្បាប់គ្មានប្រសិទ្ធភាព ដែលនាំឱ្យមានការចុះខ្សោយខាងប្រព័ន្ធនយោបាយ សមត្ថភាពរដ្ឋ ស្ថេរភាព និងសន្តិសុខរបស់ប្រពលរដ្ឋ ។

លោកឱក សេរីសោភក្ត៏ ប្រធានក្រុមប្រឹក្សាភិបាលរបស់អង្គការតម្លាភាពកម្ពុជា បានមានប្រសាសន៍ថា “*ទិវាជាតិនិងអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយគឺជាឱកាសមួយសម្រាប់ធ្វើការលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋបន្ថែមទៀតទាក់ទងនឹងផលប៉ះពាល់ដ៏អាក្រក់នៃអំពើពុករលួយ ។ យើងត្រូវតែចងចាំថាយើងទាំងអស់គ្នាសុទ្ធតែមានតួនាទីនៅក្នុងការប្រឆាំងអំពើពុករលួយ ហើយតាមរយៈកិច្ចខិតខំប្រឹងប្រែងរួមគ្នាយើងនឹងអាចទទួលបាននូវលទ្ធផលដ៏ប្រសើរជាក់ជាមិនខាន* ” ។

លោក ព្រាប កុល នាយកប្រតិបត្តិរបស់អង្គការតម្លាភាពកម្ពុជាបានថ្លែងថា “*មនុស្សគ្រប់គ្នាមានតួនាទីក្នុងការប្រឆាំងអំពើពុករលួយ ហើយមនុស្សម្នាក់ៗអាចចូលរួមប្រយុទ្ធប្រឆាំងអំពើពុករលួយបានតាមរយៈ៖*

- *មិនផ្តល់ ឬទទួលសំណូក ។*
- *តតាំងនឹងអំពើពុករលួយ និងរាយការណ៍អំពីការរំលោភបំពានទៅកាន់អង្គភាពប្រឆាំងអំពើពុករលួយតាមរយៈខ្សែទូរសព្ទលេខ ១២៨២ ឬមកកាន់អង្គការតម្លាភាពកម្ពុជាតាមរយៈខ្សែទូរសព្ទលេខ ១២៩២ ឬ ៧៧៧៧ ។*
- *រាយការណ៍ហេតុការណ៍នៃអំពើពុករលួយតាមរយៈគេហទំព័រប្រាយស្ពត (Bribespot) www.bribespot.com ឬកម្មវិធីទូរសព្ទ Bribespot ។*

ព័ត៌មានទំនាក់ទំនង៖ លោក ព្រាប កុល នាយកប្រតិបត្តិ kolpreap@ticambodia.org, (+៨៥៥)១២ ៨៧៧ ៨៣៣

- *គាំទ្របេក្ខជនឈរឈ្មោះសម្រាប់មុខងារសាធារណៈណាដែលបដិសេធនឹងអំពើពុករលួយ និងបង្ហាញពីតម្លាភាព សុចរិតភាព និងគណនេយ្យភាព ។*
- *សហការជាមួយភាគីពាក់ព័ន្ធផ្សេងទៀតដើម្បីធ្វើយុទ្ធនាការប្រឆាំងអំពើពុករលួយ ។*

**សាវតារ៖** ថ្ងៃទី០៩ ខែធ្នូ ត្រូវបានកំណត់ជាទិវាអន្តរជាតិប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការប្រយុទ្ធប្រឆាំងអំពើពុករលួយ (UNCAC) ដែលប្រទេសកម្ពុជាបានធ្វើសច្ចាប័ននៅខែកញ្ញា ឆ្នាំ២០០៧ ។ ថ្ងៃនេះអង្គការតម្លាភាពកម្ពុជាបានចេញផ្សាយនូវវីដេអូខ្លីមួយបង្ហាញពីការយល់ឃើញរបស់ប្រជាពលរដ្ឋអំពីតួនាទីរបស់ពួកគេក្នុងការប្រឆាំងអំពើពុករលួយ ។ យុទ្ធនាការលើកកម្ពស់ការយល់ដឹងតាមហ្វេសប៊ុកដែលបុគ្គលម្នាក់ៗបានចូលរួមដើម្បីចែករំលែកពីមូលហេតុរបស់ពួកគេក្នុងការប្រឆាំងអំពើពុករលួយនៅថ្ងៃនេះក៏បានបញ្ចប់ផងដែរ ។

###

***អង្គការតម្លាភាពកម្ពុជា****គឺជាតំណាងប្រចាំប្រទេសរបស់អង្គការតម្លាភាពអន្តរជាតិដែលជាអង្គការសង្គមស៊ីវិលដឹកនាំការប្រឆាំងអំពើពុករលួយទូទាំងពិភពលោក ។*

ព័ត៌មានទំនាក់ទំនង៖ លោក ព្រាប កុល នាយកប្រតិបត្តិ kolpreap@ticambodia.org, (+៨៥៥)១២ ៨៧៧ ៨៣៣